# “មាឃបូជា” តាមទំនៀមពុទ្ធសាសនិកខ្មែរ

ពុទ្ធសាសនិកខ្មែរពន្យល់ថា “មាឃបូជា” គឺជាបុណ្យប្រារព្ធដើម្បីរំឭកដល់ចតុរង្គសន្និបាតរបស់ភិក្ខុ១២៥០អង្គ និងរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធកំណត់ព្រះជន្មាយុសង្ខារ។ ព្រឹត្តិការណ៍ទាំងពីរ គេតែងសង្កេតឃើញគូរបង្ហាញនៅតាមវត្ត។ តាមឯកសារព្រះរាជពិធីទ្វាទសមាសសន្និដ្ឋានថា មាឃបូជាប្រហែលចាប់ផ្ដើមប្រារព្ធក្នុងពុទ្ធសករាជជាមួយគ្នានៃពិសាខបូជា ពោលគឺក្នុងរាជ្យព្រះបាទហរិរក្សរាមា (ព្រះអង្គដួង) កាលទ្រង់គង់នៅក្រុងឧត្តុង្គ ក្នុងពុទ្ធសករាជ២៣៩៧ គ្រិស្តសករាជ១៨៥៤។ តាំងពីដើមរៀងមក ពិធីនេះក៏ចាត់ជាព្រះរាជពិធីបុណ្យ ដែលព្រះមហាក្សត្រតែងយាងបំពេញព្រះរាជកុសល តាមព្រះរាជប្រវេណីក្នុងថ្ងៃ១៥កើត ខែមាឃ (រូបលេខ១)។[១] រីឯប្រជារាស្ត្រទូទៅក៏ប្រារព្ធនៅតាមវត្តអារាមនានាក្នុងថ្ងៃពេញបូណ៌មីខែមាឃនេះដែរ។



រូបលេខ១ ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យយាងបំពេញព្រះរាជកុសលក្នុងព្រះរាជពិធីបុណ្យមាឃបូជាក្នុងព្រះវិហារព្រះកែវមរកត នៃព្រះបរមរាជវាំង (ប្រភព៖ **https://norodomsihamoni.org**)

[១] ចាប ពិន ១៩៦០: ១៤៩-១៥៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិតកាលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅជាធរមាន មានហេតុពីរប្រការគឺការប្រជុំចតុរង្គសន្និបាតនៃភិក្ខុ១២៥០អង្គ និងការកំណត់ព្រះជន្មាយុសង្ខាររបស់ព្រះអង្គនៅក្នុងថ្ងៃ១៥ កើត ខែមាឃ។ ពុទ្ធសាសនិកចាត់ទុកថា ចតុរង្គសន្និបាតនោះគឺជាសន្និបាតដ៏អស្ចារ្យប្រកបដោយអង្គបួន ហើយកើតឡើងតែម្តងគត់ក្នុងសម័យពុទ្ធកាល ពោលគឺទី១ កើតឡើងចំថ្ងៃ១៥កើត ពេញបូណ៌មីខែមាឃ។ ទី២ភិក្ខុទាំង១២៥០អង្គ និមន្តចូលរួមសុទ្ធតែជាព្រះអរហន្តជាន់ខ្ពស់។ ទី៣ភិក្ខុទាំង១២៥០អង្គ បាននិមន្តមកដោយចិត្តឯងគ្មានការគ្រោងទុកមុន និងទី៤គឺភិក្ខុទាំង១២៥០អង្គ សុទ្ធតែជាឯហិភិក្ខុដែលបួសភ្លាមៗក្រោយព្រះពុទ្ធទ្រង់អនុញ្ញាត។ តាមរយៈសិល្បៈគំនូរតាមវត្ត គេឃើញត្រង់ឈុតចតុរង្គសន្និបាតនេះតែងគូរបង្ហាញព្រះសម្មាសម្ពុទ្ធគង់កណ្តាលចំណោមភិក្ខុរាប់ពាន់អង្គនៅក្នុងព្រៃឫស្សីដូចសេចក្តីចែងក្នុងពុទ្ធប្រវត្តិ (រូបលេខ២-៣)។[២]




រូបលេខ២-៣ ចតុរង្គសន្និបាតក្នុងព្រៃស្សីនៃភិក្ខុទាំង១២៥០អង្គ (គំនូរវត្តពាមង្គល និងវត្តក្បៀតសិម្ពិលី)

ដោយឡែក ចំពោះការណ៍ដែលព្រះពុទ្ធអង្គទ្រង់បានកំណត់ព្រះជន្មាយុសង្ខារ គឺចំពេលចេញវស្សាទី៤៥ ក្នុងព្រះជន្មាយុ៨០ព្រះវស្សា នាថ្ងៃ១៥កើត ពេញបូណ៌មីខែ មាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ប្រកាសដាក់អាយុសង្ខារដោយប្រាប់មារថា ព្រះអង្គនឹងចូលបរិនិព្វានក្នុងរយៈពេលបីខែទៀត។ សេចក្តីត្រង់នេះបើពិនិត្យមើលលើសិល្បៈគំនូរគេតែងសង្កេតឃើញគូរបង្ហាញព្រះពុទ្ធអង្គគង់លើបល្ល័ង្កក្រោមដើមឈើ ហើយមានមារម្នាក់មក

[២] Gunapayuta et al. 1998: 153-155 និងគណៈកម្មការធម្មវិន័យ ១៩៨៩: ៤៦-៥៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ថ្វាយបង្គំអារាធនាព្រះអង្គឱ្យចូលនិព្វាន។ ព្រះអង្គរព្ញកនឹកឡើងថា នេះដល់វេលាដែលព្រះតថាគតត្រូវរៀបចំព្រះដំណើរយាងចូលនិព្វានស្ថានបរមសុខ នឹងមិនត្រឡប់កើតមកក្នុងលោកឯណាមួយវិញឡើយ (រូបលេខ៨-៩)។[៣]



រូបលេខ៨ កាលព្រះអង្គដាក់ព្រះជន្មាយុសង្ខារ (គំនូរវត្តក្បៀតសិម្ពលី)



រូបលេខ៩ កាលព្រះអង្គដាក់ព្រះជន្មាយុសង្ខារ (គំនូរវត្តមង្គលវង្ស, រូបថត៖ ព្រាប ចាន់ម៉ារ៉ា)

ព្រឹត្តិការណ៍យ៉ាងសំខាន់ទាំងពីរ ដែលកើតឡើងក្នុងសម័យពុទ្ធកាលនេះ បានដក់ក្នុងចិត្តពុទ្ធសាសនិកខ្មែរតាមរយៈសិល្បៈគំនូរបង្ហាញនៅតាមវត្ត និងជាពិសេសបំផុតគឺការរៀបចំប្រារព្ធមាឃបូជា ដើម្បីរំឭកជារៀងរាល់ឆ្នាំ(រូបលេខ៦-៧)។ ពាក់ព័ន្ធនឹងរបៀបឬដំណើរនៃការរៀបចំពិធីបុណ្យមាឃបូជាក្នុងសង្គមខ្មែរក្រៅពីព្រះរាជពិធីក្នុងព្រះបរមរាជវាំង គេសង្កេតឃើញមានទិដ្ឋភាពពីសំខាន់គឺ នៅព្រឹកនិងពេលយប់ នៃថ្ងៃ១៥កើតពេញបូណ៌មី។ ជាធម្មតានៅពេលព្រឹក នៅតាមវត្តមួយចំនួនព្រះសង្ឃតែងដឹកនាំ

---

[៣] ព្រាប ចាន់ម៉ារ៉ា ២០១៣: ៩៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ពុទ្ធបរិស័ទដង្ហែព្រះពុទ្ធបដិមា ឬព្រះបរមសារីរិកធាតុនិងគ្រឿងសក្ការៈផ្សេងៗតាមផ្លូវនានាក្នុងភូមិស្រុក ឬឆ្ពោះទៅបូជនីយដ្ឋានគោរពបូជាក៏មាន (រូបលេខ៨-៩)។ ប៉ុន្តែនៅតាមវត្តខ្លះ គេពូនភ្នំខ្សាច់ ឬរៀបចំស្អិតស្អាងព្រះពុទ្ធបដិមាគោរពបូជា ឬនិមន្តព្រះសង្ឃរាប់បាត្រ (រូបលេខ១០-១១)។



រូបលេខ៦ ការរៀបចំអនុមោទនាបុណ្យមាឃបូជានៅវត្តលលៃ



រូបលេខ៧ ការរៀបចំអនុមោទនាបុណ្យមាឃបូជាតាមដងផ្លូវនៅខេត្តបន្ទាយមានជ័យ



រូបលេខ៨ ក្បួនដង្ហែមាឃបូជានៅប្រាសាទព្រះវិហារ (រូបថត៖ ក្រសួងវប្បធម៌)



រូបលេខ៩ ក្បួនដង្ហែមាឃបូជានៅវត្តព្រែកអំបិល (រូបថត៖ វត្តព្រែកអំបិល)





រូបលេខ១០-១១ ទិដ្ឋភាពពិធីបុណ្យមាឃបូជានៅវត្តដំណាក់ ខេត្តសៀមរាប ឆ្នាំ២០១៤

នៅវេលារាត្រីក្នុងថ្ងៃដដែល ពុទ្ធបរិស័ទជិតឆ្ងាយតែងរៀបចំគ្រឿងសក្ការៈផ្សេងៗសម្រាប់បូជាព្រះរតនត្រ័យដូចជា ទៀន ធូប ប្រទីប និងផ្កាភ្ញីដែលភាគច្រើនរៀបចំថ្វាយចំពោះព្រះភក្ត្រព្រះពុទ្ធបដិមាក្នុងព្រះវិហារ។ បន្ទាប់មកគេក៏រៀបចំនមស្ការព្រះរតនត្រ័យនិមន្តព្រះសង្ឃសូត្រមន្ត និងចម្រើនព្រះបរិត្តទៅតាមលំអានព្រះពុទ្ធសាសនា។ រួចពីនោះមកទើបលោកអាចារ្យ ឬព្រះថេរអង្គណាមួយដែលមានភាពឈ្លាសជាងគេ ក៏ក្រោកឡើងហើយសូត្រប្រកាសមាឃបូជា (រូបលេខ១២)។ សេចក្តីប្រារព្ធមាឃបូជានោះ គឺផ្តើមដោយ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

កិច្ចវេរគ្រឿងសក្ការៈ និងបទនមសក្ការ រួចទើបសូត្របទគាថាប្រារព្ធមាឃបូជា ដែលបុរាណលោកបានប្រែសេចក្តី និងចងក្រងជាពាក្យកាព្យយ៉ាងពីរោះ។[៦] ទន្ទឹមនឹងនេះ នៅតាមវត្តភាគច្រើនតែងរៀបចំអុជប្រទីបផ្កាលា ឬបង្ហោះគោមក្នុងរាត្រី១៥ កើតខែមាឃ។



រូបលេខ១២ ព្រះសង្ឃនិមន្តសូត្រប្រកាសមាឃក្នុងព្រះវិហារ វត្តព្រះឥន្ទ្រកោសា, សៀមរាប

សរុបសេចក្តីមកមាឃបូជា ជាថ្ងៃប្រារព្ធរំឭកដល់ហេតុអស្ចារ្យពីរគឺការប្រជុំចតុរង្គសន្និបាត និងការកំណត់ព្រះជន្មាយុសង្ខាររបស់ព្រះសម្មាសម្ពុទ្ធ នៅក្នុងថ្ងៃ១៥ កើតខែមាឃ។ ក្នុងថ្ងៃនេះ ទាំងព្រះមហាក្សត្រនិងប្រជារាស្ត្រទូទៅ បានទុកជាថ្ងៃបំពេញព្រះរាជកុសលនិងសាងកុសលដ៏ធំធេងតាមលំអានព្រះពុទ្ធសាសនា៕

[៦] សូមអាន៖ មាឃបូជា វិសាខបូជា និងពិធីពុទ្ធាភិសេក ដោយគណៈកម្មការធម្មវិន័យ, ១៩៨៩: ៤៦-៥៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារពិគ្រោះ

គណៈកម្មការធម្មវិន័យ

១៩៨៩, មាឃបូជា ពិសាខបូជា និងពុទ្ធាភិសេក, បណ្ណាគារឃោឃតា, ភ្នំពេញ

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៣, *វត្តមង្គលវង្ស*, (?), ភ្នំពេញ

Gunapauta et al,

1998, *Biography of Sakyamuni Buddha,* The Buddha Educational Foundation, Sydney

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត